ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ
សាលក្រមលេខ ០៧ "ញ"
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧
សំណុំរឿងព្រហ្មទណ្ឌលេខ ៦៣៩
ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាជម្រះក្តី នៃសាលាដំបូងខេត្តបន្ទាយមានជ័យ កាលបរិច្ឆេទបើកសវនាការ៖ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ០៨ និង ៣០ នាទីរសៀល ។

ដោយមានសមាសភាពដូចតទៅ

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៦៣៩ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ ទីកន្លែងកំណើតនៅភូមិត្បូងឃ្មុំ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុន គ្មាន។

ឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ។

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) បទល្មើសចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤ ចំណុចទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលអំឡុង



Scanned by CamScanner

ឆ្នាំ២០១៦ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៧៥៨ អ.យ.គ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ ដីកាដំណោះស្រាយលេខ ៧៨៨៧ ពស.ព្រទ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧៩៨ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដែលធ្វើឡើងដោយអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## អង្គហេតុកើតឡើងមានដូចតទៅ

កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ០០ នាទី កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត បានចុះល្បាតបង្រ្កាបករណីជួញដូរ និងប្រើប្រាស់ថ្នាំញៀនខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិ បាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] និងឈ្មោះ [redacted] បានដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីនទឹកកកចំនួន ១៩ (ដប់ប្រាំបួន) កូនថង់តូច ។ ក្រោយពីបានសាកសួរឈ្មោះ [redacted] បានសារភាពថាខ្លួន បានលក់ថ្នាំញៀនមួយរយៈពេលកន្លងមកហើយ ដោយទិញពីឈ្មោះ [redacted] ភេទប្រុស ទិញម្តងចំនួន ៣,០០០ (បីពាន់) បាត យកមកលក់ជាថង់តូចៗដើម្បីលក់បន្ត ចំណែកឯ ឈ្មោះ [redacted] ជាអ្នកប្រើប្រាស់ថ្នាំញៀនត្រូវបញ្ជូនខ្លួនទៅមណ្ឌលជីវិតថ្មីភ្នំបាក់ ខេត្តបន្ទាយ មានជ័យ ដើម្បីទទួលការព្យាបាល និងស្តារនីតិសម្បទា ។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានលក់ថ្នាំញៀនអស់ប្រហែល ១០ (ដប់) កញ្ចប់ ក្នុងមួយថ្ងៃចំណេញបាន ១០០,០០០ (ដប់ម៉ឺន) រៀល នៅពេលដែលសមត្ថកិច្ចចាប់ឃាត់ខ្លួននោះខ្លួនកំពុងតែលេងបៀ ហើយសមត្ថកិច្ចបានដកហូតថ្នាំញៀនបាន ១៩ (ដប់ប្រាំបួន) កញ្ចប់ ខ្លួនសូមសារភាពទាំងអស់ ខ្លួនពិតជាបានជួញដូរថ្នាំញៀនដូចការចោទប្រកាន់ពិតមែន ខ្លួនចាប់ផ្តើមលក់ថ្នាំញៀនដោយសារខ្លួនអត់មានការងារធ្វើ ដំបូងខ្លួនធ្វើការសំណង់តែបានប្រាក់ខែតិចពេក ខ្លួនពុំបានរៀនសូត្រនោះទេ ហើយក៏មិនចេះអក្សរនោះដែល ខ្លួនមានកូន០២នាក់ អាយុ០២ឆ្នាំ និងអាយុ០៨ឆ្នាំ ខ្លួនសូមឱ្យតុលាការជួយសម្រាលទោសឱ្យខ្លួនផង ។

-តំណាងអយ្យការបានសន្និដ្ឋានថា៖ ឆ្លងតាមស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ និងចម្លើយជនជាប់ចោទ, ចម្លើយសាក្សី ព្រមទាំងមូលក្នុងអង្គសវនាការ ឃើញថាពិតជាមានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) បទល្មើសចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៥ ខែ

Scanned by CamScanner

សីហា ឆ្នាំ២០១៦ ពិតប្រាកដ ហេតុដូច្នេះសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរដដែល និងម្យ៉ាងទៀត ឃើញថាជនជាប់ចោទបានសារភាពដឹងកំហុស ម្យ៉ាងទៀតទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ ហើយបានសហការណ៍ជាមួយតុលាការបានល្អ ហេតុនេះ សុំឱ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទ ឆាប់បានចេញទៅរកស៊ីចិញ្ចឹមគ្រួសារ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ ក្នុងអង្គសវនាការ និងស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថាកូនក្តីខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ ហេតុនេះស្នើសុំតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ដើម្បីកូនក្តីខ្លួនឆាប់បានវិលត្រឡប់ជួបជុំគ្រួសារវិញ ។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបាន ស្តាប់តាមអំណានចម្លើយរបស់សាក្សី ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ។

-ក្រោយពីបាន ពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## យល់ឃើញថា

១-កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ០៨ នាទី មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) នៅចំណុចភូមិ បាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្ត បន្ទាយមានជ័យ ដែលប្រព្រឹត្តដោយឈ្មោះ [redacted] ពិតប្រាកដ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនចាប់ផ្តើមរកស៊ីជួញដូរគ្រឿងញៀន នៅអំឡុងឆ្នាំ២០១៦ នេះដោយខ្លួនបានទិញពីឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ។ ខ្លួនទិញថ្នាំញៀនម៉ាកទឹកកកម្តងៗតម្លៃ ៣,០០០ (បីពាន់) បាត ដោយទិញពីឈ្មោះ [redacted] ហើយយកទៅវែកលក់បន្តដើម្បីបានចំណេញដោយម្តងៗចំណេញបាន ១០០,០០០ (ដប់ម៉ឺន) រៀល ។ ខ្លួនយកថ្នាំញៀននោះទៅលក់ឱ្យកម្មករសំណង់ ។ ខ្លួនមិនចាំចំនួនដងនៃការទិញលក់ថ្នាំញៀនយកទៅលក់នោះទេ ប៉ុន្តែខ្លួនគ្រាន់តែដឹងថារយៈពេល ០២ ថ្ងៃ ទៅ ០៣ ថ្ងៃ ខ្លួនទិញម្តងដើម្បីយកមកលក់បន្តរហូតដល់ថ្ងៃ ដែលសមត្ថកិច្ចឃាត់ខ្លួន ។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ម៉ោង ១៨ និង ០០ នាទី ខ្លួនកំពុងលេងបៀនៅក្នុងផ្ទះទុកចោល ស្ថិតនៅភូមិបាលិលេយ្យ២ ជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted]។ ពេលនោះមានមនុស្សប្រុសម្នាក់មកទិញថ្នាំញៀនពីឈ្មោះ [redacted] ពេលដែលឈ្មោះ [redacted] យកថ្នាំញៀនឱ្យទៅអ្នកទិញក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះខ្លួនមិនបានទិញលក់ថ្នាំញៀននោះទេ ប៉ុន្តែនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ម៉ោង ០៥ ល្ងាច ខ្លួនបានលក់ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០២ (ពីរ) កញ្ចប់តូចមានតម្លៃ ៥០,០០០ (ប្រាំម៉ឺន) រៀល ឱ្យកម្មករសំណង់ដោយខ្លួននៅចំណុចភូមិបាលិលេយ្យ២។ សមត្ថកិច្ចបានដកហូតថ្នាំញៀនចំនួន ១៥ (ដប់ប្រាំបួន) កូនថង់តូច ដែលថ្នាំញៀននោះជា របស់ខ្លួន និងទូរស័ព្ទដៃមិនស្គាល់ម៉ាកចំនួនមួយគ្រឿង ។

៣-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនចំនួន ០៣ ខែ មកហើយរហូតដល់ថ្ងៃដែលសមត្ថកិច្ចបានចាប់ឃាត់ខ្លួន ហើយថ្នាំញៀនខ្លួនបាន

Scanned by CamScanner

ទិញពីឈ្មោះ [redacted] ចំនួន ០៦ ទៅ ០៧ ដង ដោយទិញនៅអំឡុងឆ្នាំ២០១៦ ទិញនៅភូមិបាលិលេយ្យ២។ ខ្លួនទិញថ្នាំញៀនពីឈ្មោះ [redacted] មួយកញ្ចប់តម្លៃ ២០,០០០ (ពីរម៉ឺន) រៀល ទៅ ៣០,០០០ (បីម៉ឺន) រៀល ។ នៅថ្ងៃចុងក្រោយខ្លួនទិញថ្នាំញៀនពីឈ្មោះ [redacted] នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ម៉ោង ០២ រសៀល ខ្លួនទិញថ្នាំញៀនប្រភេទម៉ាកទឹកកកចំនួន ០១ កញ្ចប់តូចតម្លៃ ២០,០០០ (ពីរម៉ឺន) រៀល ដោយទិញនៅក្នុងផ្ទះគេទុកចោលនៅភូមិបាលិលេយ្យ២ ។ ពេលទិញបានហើយ ខ្លួនបានជក់ថ្នាំញៀននៅផ្ទះទុកចោលនោះ និងបានលេងបៀជាមួយឈ្មោះ [redacted] នៅផ្ទះទុកចោលនោះ ។ ហូតដល់ម៉ោង ០៥ ល្ងាច ដដែល ខ្លួនបានឃើញមនុស្សម្នាក់ទិញថ្នាំញៀនពីឈ្មោះ [redacted] តម្លៃ ៥០,០០០ (ហ្រាំម៉ឺន) រៀល ខណៈនោះក៏មានសមត្ថកិច្ចមកឃាត់ពួកខ្លួននៅនឹងផ្ទះទុកចោលនោះតែម្តង ។

៤-តាមចម្លើយជនជាប់ចោទខាងលើនេះអាចឱ្យតុលាការជឿបាន ព្រោះស៊ីសង្វាក់ទៅនឹងរបាយការណ៍ និង សេចក្តីសន្និដ្ឋានរបស់មន្ត្រីនគរបាលយុត្តិធម៌ព្រមទាំងស៊ីសង្វាក់ទៅនឹងវត្ថុចាប់យកដែលជាថ្នាំញៀនរបស់ជនជាប់ចោទឈ្មោះ តូច ម៉ោ ហើយក៏ពុំមានភស្តុតាងណាផ្ទុយពីនោះដែរ។

៥-តាមភស្តុតាងនានា ចម្លើយរបស់សាក្សី ចម្លើយរបស់ជនជាប់ចោទបាន បង្ហាញថាឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់ចៅក្រមស៊ើបសួរតាមរយៈដីកាដំណោះស្រាយលេខ ៧៨៨៧ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ពិតប្រាកដមែន។

៦-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៧៦៣៥/១៦ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាលទ្ធផល វិជ្ជមាន សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine) មានបរិមាណសារធាតុ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ ៧៥.៩៨% (ចិតសិបប្រាំក្បៀសកៅសិបប្រាំបី) ភាគរយ ស្ថិតនៅក្នុងតារាងទី II មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧-វត្ថុចាប់យកមាន ថ្នាំញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ១៥ (ដប់ប្រាំ) កញ្ចប់តូចមានទម្ងន់ស្មើ ២.២៣ (ពីរក្បៀសម្ភៃបី) ក្រាម ថ្លឹងទាំងសំបកថង់ ជាកម្មវត្ថុនៃបទល្មើសគប្បីតុលាការ សម្រេចរឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីបំផ្លាញចោល ។

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ។ ចម្លើយសារភាពរបស់ជនជាប់ចោទបានបញ្ជាក់ឱ្យឃើញថា នូវធាតុអត្តនោម័ត គឺចេតនាប្រព្រឹត្តរបស់ជនជាប់ចោទ រីឯថ្នាំញៀនដែលជាវត្ថុចាប់យកជាធាតុសម្ភារម័ត។ ចំពោះធាតុនីត្យានុកូល អំពើរបស់ជនជាប់ចោទជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) តាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលអំឡុង ឆ្នាំ២០១៦ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ។

៩-ជនជាប់ចោទឈ្មោះ [redacted] ជាសមត្ថជន មាននិតិសម្បទាគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ។ ជនជាប់ចោទអាចពិចារណាបាននូវចំណងទាក់ទង

Scanned by CamScanner

ហេតុនិងផល អំពើនិងបច្ច័យដែលកើតឡើងដោយសារការប្រព្រឹត្តរបស់ខ្លួន តែជនជាប់ចោទនៅតែប្រព្រឹត្តដោយចេតនា ក្នុងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលធ្វើឱ្យប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋ, សណ្តាប់ធ្នាប់សាធារណៈ និង សន្តិសុខ សុវត្ថិភាពសង្គម ។ ជននេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាល់របស់ខ្លួនដូច មានក្នុងបទបញ្ញត្តិមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ។

១០-តំណាងអយ្យការបានសន្និដ្ឋានថា៖ ឆ្លងតាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ និងអំណានចម្លើយសាក្សីក្នុងអង្គសវនាការ និងស្តាប់អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន ឃើញថា លទ្ធផលមានវត្តមានសារធាតុញៀន និងមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោ[redacted]។ ដូច្នេះប្តឹងសុំឱ្យតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទ តាមច្បាប់ និងផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទ ដោយហេតុថា ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ និងខ្វះការយល់ដឹង ។ តុលាការយល់ឃើញថា ការសន្និដ្ឋានរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណាឱ្យសមស្របតាមការប្តឹងសុំ ។

១១-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក[redacted]បានស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ដើម្បីកូនក្តីខ្លួនឆាប់បានវិល ត្រឡប់ជួបជុំគ្រួសារ ។ សេចក្តីសន្និដ្ឋានរបស់មេធាវីនេះ មានហេតុផលត្រឹមត្រូវតាមច្បាប់អាចឱ្យតុលាការពិចារណាបាន ។

១២-តាមសំអាងហេតុខាងលើ និងក្រោយពីបានពិចារណាទៅលើភស្តុតាង សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរួចមកតុលាការបានរកឃើញនូវ កំហុសរបស់ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដែលមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) ត្រូវផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង

ញៀន ប្រាកដមែន ។

១៣-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស ខ្វះការយល់ដឹង, មានជីវភាពក្រីក្រ និងទើបតែប្រព្រឹត្តជាលើកទី១ ម្យ៉ាងទៀតជនជាប់ចោទបានឆ្លើយសារភាពនូវអំពើរបស់ខ្លួន ដោយឥតលាក់លៀមសហការជាមួយសមត្ថកិច្ច និងតុលាការបានល្អ ។ ដោយហេតុដើម្បីឱ្យជនជាប់ចោទក្លាយខ្លួនជាពលរដ្ឋដ៏ល្អនៅក្នុងសង្គមជាមនុស្សល្អវិញ ។ តុលាការពិចារណាក្នុងការព្យួរទោសដោយប្រកាសទោសត្រឹមកម្រិតអប្បបរមានៃទោសដែលច្បាប់កំណត់តាមមាត្រា មាត្រា៤០ កថាខណ្ឌទី៥ ចំណុច ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងព្យួរទោសធម្មតាមួយផ្នែកនៃទោសពន្ធនាគារឱ្យដល់ជនជាប់ចោទឈ្មោះ[redacted]ព្រោះជនជាប់ចោទរូបនេះ មិនទាន់មានការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេលប្រាំឆ្នាំមុនអំពើល្មើសនេះទេ ។ ម្យ៉ាងទៀតទោសដែលប្រកាសស្មើនិងប្រាំឆ្នាំទៀតផង ។ ផ្អែកតាមមាត្រា ១០៦, មាត្រា ១០៧ និង មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ និងប្រកាសទោសពិន័យត្រឹមកម្រិតអតិបរមានៃទោសពិន័យមាត្រា៤០ កថាខណ្ឌទី៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned by CamScanner

១៤-ជនជាប់ចោទឈ្មោះ [redacted] បាននិយាយសំដីចុងក្រោយសុំឱ្យតុលាការជួយសម្រាលទោសឱ្យខ្លួនផង សំណូមពរនេះតុលាការនឹងយកមកពិចារណា ។

១៥-ជនជាប់ចោទឈ្មោះ [redacted]ានមកបង្ហាញខ្លួននៅនៅចំពោះមុខសវនាការ ។ ដូចនេះ សាលក្រមត្រូវប្រកាសចំពោះមុខឈ្មោះ [redacted]តាមមាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២១ ឆ្នាំ មានពិរុទ្ធភាពពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ច្រើនដង) ប្រព្រឹត្តនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ បទល្មើសចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

I-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ តែត្រូវអនុវត្តទោសក្នុងពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ និង ០៦ ខែ ទោសដែលនៅសល់ពីនេះត្រូវព្យួរធម្មតាតាមមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០ (ដប់លាន) រៀល ។

II-វត្ថុចាប់យកមាន ថ្នាំញៀនប្រភេទម្សៅក្រាមពណ៌សថ្លាចំនួន ១៥ (ដប់ប្រាំ) កញ្ចប់តូច មានទម្ងន់ស្មើ ២.២៣ (ពីរកេណ្ណក់សញ្ញាម្ភៃបី) ក្រាម ថ្លឹងទាំងសំបកថង់ សម្រេចរឹបអូសតាមមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និង ត្រា
[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
បន្ទាយមានជ័យ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧
ក្រឡាបញ្ជី
[redacted]



Scanned by CamScanner